**ព្រះរាជាណាចក្រកម្ពុជា**

**តុលាការកំពូល** **ជាតិ សាសនា ព្រះមហាក្សត្រ**

សំណុំរឿងព្រហ្មទណ្ឌ **តាងនាមប្រជារាស្ត្រខ្មែរ**

លេខ : ០៥ **តុលាការកំពូល**

ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៦

**សាលដីកា**

លេខ : ៤១

ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៦

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៦ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** ប្រធាន

២- លោក ឈឹម ស៊ីផល ចៅក្រម

៣- លោក វៀល មួន ចៅក្រម

៤- លោក ស៊ិន ឌឹម ចៅក្រម

៥- លោក យស់ សូខឿន ចៅក្រមរបាយការណ៍

ក្រឡាបញ្ជី

លោក **គឹម ដារទ្ធី**

តំណាងមហាអយ្យការ

ឯកឧត្តម **ជួន ស៊ុនឡេង** អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ២៦ "ខ" ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ០៥ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៦ របស់តុលាការកំពូល ។

***ពីបទ*** : ឃុបឃិតគ្នាយកផ្ទះទៅលក់ និង រំលោភកិច្ចការប្រញាប់ ។

-ជនត្រូវចោទឈ្មោះ **សេង សាញ់** "ជាចុងបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៥២ឆ្នាំ ជាតិខ្មែរ របររកស៊ីចៅសង្កាត់ ទីលំនៅសព្វថ្ងៃផ្ទះលេខ៣៨៦ ក្រុមទី៨ ភូមិឫស្សី សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ សេង សុន "ស" ម្តាយឈ្មោះ សេង ម៉ៅ "ស" ប្រពន្ធឈ្មោះ ហែម ស៊ីថាន មានកូន០៣នាក់ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **សុខ ពៅ** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៦៧ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ៨១E₀ ផ្លូវរោងចក្រកែវ សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ។

-មានមេធាវី លោក គិក ភូរិ

តាមពាក្យបណ្តឹង ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០២ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះសុខ ពៅ ប្តឹងពីឈ្មោះសេង សាញ់ ឃុបឃិតគ្នាយកផ្ទះខ្លួនលក់ឱ្យអ្នកដទៃ ពេលដីកាសំរេចកិច្ចការប្រញាប់កំពុងអនុវត្ត តុលាការក្រុងភ្នំពេញសំរេចហាមឃាត់សាលាក្រុងមិនអោយលក់ ដូរ ជួល បញ្ចាំ ផ្ទេរសិទ្ធិ និងធ្វើអំណោយទៅអ្នកដទៃនូវផ្ទះលេខ៤១$E_0E_1$ទាំងមូល ស្ថិតនៅភូមិថ្មី ក្រុម៣ សង្កាត់ស្ទឹងមានជ័យ ក្រុងភ្នំពេញ ទុកជាបណ្តោះអាសន្ន រងចាំ តុលាការសំរេចដល់អង្គសេចក្តី ។

-បានឃើញដីកាតម្កល់រឿងទុកឥតចាត់ការលេខ១០២៧ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០២ របស់អយ្យការ អមតុលាការក្រុងភ្នំពេញ ដែលបានសំរេច : តម្កល់រឿងនេះទុកមិនចាត់ការតទៅ ។

-បានឃើញបណ្តឹងឧទ្ធរណ៍២១ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០២ របស់ឈ្មោះសុខ ពៅ ដែលប្តឹងមិនសុខចិត្តនឹងដីកាតម្កល់រឿងទុកឥតចាត់ការលេខ១០២៧ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០២ របស់អយ្យការ អមតុលាការក្រុងភ្នំពេញ លើដីកាសំរេចទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា : គួរតម្កល់ដីកាសំរេចតម្កល់រឿងទុកឥតចាត់ការ ទុកជាបានការដដែល ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ២៦"ខ" ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៥ របស់សាលា-ឧទ្ធរណ៍ ដែលបានសំរេច :

១/-ទទួលបណ្តឹងឧទ្ធរណ៍លេខ២១ ចុះថ្ងៃទី១៧-៥-២០០២ របស់ឈ្មោះ សុខ ពៅ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ បដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់ដីកាសំរេចរឿងទុកឥតចាត់ការលេខ១០២៧ ចុះថ្ងៃទី០៣-៥-២០០២ របស់អយ្យការ អមតុលាការក្រុងភ្នំពេញទុកជាបានការពេញទាំងមូល ។

៣-ដីកានេះមានអានុភាពអនុវត្តភ្លាមៗ ។

សាលដីកានេះ ជំនុំជំរះនិងប្រកាសជាសាធារណៈកំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវសាទុក្ខតាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ១១១ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៥ របស់ឈ្មោះសុខ ពៅ ប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ២៦"ខ" ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណា ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៦ របស់ឈ្មោះ សុខ ពៅ "ជាម្ចាស់បណ្តឹងសាទុក្ខ" ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានឃើញសារណាតប ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៦របស់ឈ្មោះសេង សាញ់ "ជាចុងបណ្តឹងសាទុក្ខ" ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានស្តាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា :រឿងនេះជារឿងរបស់សាលាក្រុងភ្នំពេញ មិនមែនជារឿងរបស់ចៅសង្កាត់ទេ ។ សូមតំកល់សាលដីកាព្រហ្មទណ្ឌលេខ២៦"ខ" ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

-បានស្តាប់ចម្លើយអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ សុខ ពៅ "ជាចុងបណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះថា : ឆ្នាំ១៩៧៩ លោកសេង សាញ់ ជួយរកម៉ូយអោយនាងខ្ញុំ លក់ផ្ទះនាងខ្ញុំបាន៩.០០០$ (ប្រាំបួនពាន់ដុល្លា) ប្រាប់នាងខ្ញុំថា ដាក់ទីស្នាក់ការ ស្រាប់តែដាក់អោយជាងថតរូបទៅវិញ បន្ទាប់មកទៀតដាក់អោយជួលលក់ទូរស័ព្ទដៃ ដល់នៅឆ្នាំ១៩៩៨ លោកសេង សាញ់ បានឡើងជាប្រធានសង្កាត់បន្ទាប់មកការទាមទារពីរឿងផ្ទះរបស់នាងខ្ញុំ មិនបានផលអ្វីសោះសំរាប់នាងខ្ញុំ ។ ទើបនាងខ្ញុំមិនសុខចិត្តក៏បានប្តឹងលោកសេង សាញ់ បានឃុបឃិតយកផ្ទះនាងខ្ញុំលក់ និងជួល ដែលមានលេខ៤១E₀ . ៤១E₁ ៤២E₀ . ៤២E₁ ។ សំណូមពរ សូមយកផ្ទះនាងខ្ញុំទាំងអស់វិញ សូមឯកឧត្តមប្រធានជួយរកយុត្តិធម៌ឱ្យនាងខ្ញុំផង ។

-បានស្តាប់ចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ សេង សាញ់ "ជាចុងបណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះថា : ខ្ញុំបាទពុំបានយកផ្ទះរបស់ សុខ ពៅ ទៅលក់អោយអ្នកដទៃដូចការលើកឡើងនៅក្នុងសារណារបស់ខ្លួននោះឡើយ ។ សុខ ពៅ និយាយនេះមិនត្រឹមត្រូវទេ ព្រោះថា ឆ្នាំ១៩៩៨ ខ្ញុំបាទទើបឡើងធ្វើជាមេឃុំ រីឯការប្រគល់ផ្ទះទំនាស់ឱ្យទៅកងរាជអាវុធហត្ថនេះ គឺពុំពាក់ព័ន្ធនិងសមត្ថកិច្ចគ្រប់គ្រងរបស់ខ្ញុំបាទឡើយ ។ សំណូមពរ សូមតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក អ៊ុក ភួរិ ជាមេធាវីការពារអោយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះសុខ ពៅ "ជាម្ចាស់បណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះថា : រឿងនេះមិនទាន់ចប់ជាស្ថាពរ ព្រោះថាជារឿងនៅក្តីក្តាំនៅឡើយ តាមពិតអ្នកនៅកាន់កាប់ផ្ទះរបស់អ្នកស្រី សុខ ពៅ មាន៦គ្រួសារទៅហើយមិនមានកងរាជអាវុធហត្ថអ្វីនោះទេ ព្រោះថា លោកសេង សាញ់ ជាចៅសង្កាត់ត្រូវទទួលការដឹងលឺថាអ្នកណាចូលមកនៅ តាមពិតគ្មាន PM រឺកងរាជអាវុធហត្ថមកនៅដូចពាក្យលោកសេង សាញ់ នោះនិយាយ ធាតុពិតមានតែឯកជនរស់នៅផ្ទះរបស់អ្នក សុខ ពៅ តែប៉ុណ្ណោះ ។

ឯកឧត្តម ហង្សរ៉ា រ៉ាគេន ក៏ពិនិត្យរួចហើយដែរ ចំណែកតុលាការក្រុងភ្នំពេញក៏ដូចសាលាឧទ្ធរណ៍មិនបានពិនិត្យត្រឹមត្រូវឡើយ វាជាកំហុសធ្ងន់ធ្ងរណាស់ចំពោះរឿងនេះ។ សំណូមពរ ចៅក្រមស៊ើបអង្កេតគប្បីស៊ើបឡើងវិញអោយបានត្រឹមត្រូវ សូមឯកឧត្តមប្រធាន មេត្តាបង្វិលសំណុំរឿងនេះទៅសាលា-ឧទ្ធរណ៍ដើម្បីស៊ើបអង្កេតឡើងវិញ ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូល នៅពេលជំនុំជំរះថា : រឿងនេះគឺជារឿងពាក់ព័ន្ធការទិញលក់ផ្ទះ មិនមានការពាក់ព័ន្ធរឿងព្រហ្មទណ្ឌទេ គឺជារឿងរដ្ឋប្បវេណី តែជនរងគ្រោះប្តឹងចៅសង្កាត់ជារឿងព្រហ្មទណ្ឌ គួរពិចារណា ព្រោះបុគ្គលដែលត្រូវតែប្តឹង

មិនអាចមានកំហុសក្នុងរឿងព្រហ្មទណ្ឌឡើយ ហើយក៏មិនមានភស្តុតាងណាជាលាយល័ក្ខអក្សរដែរ សូមតម្កល់ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីអ្នកស្រីសុខ ពៅ និងចម្លើយរបស់ជនជាប់ចោទឈ្មោះសេង សាញ់ សេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី .

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១១១ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៥ របស់អ្នកស្រី សុខ ពៅ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន តាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ផ្ទះដែលជាកម្មវត្ថុនៃការប្តឹងចោទប្រកាន់នេះត្រូវបានអាជ្ញាធរក្រុងភ្នំពេញ តាមសេចក្តីសំរេចលេខ៣៧៤ សល ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៤ ប្រគល់អោយទៅកងរាជអាវុធហត្ថប្រចាំរាជធានីភ្នំពេញរួចហើយ ដូច្នេះការចាត់ចែងរឿងផ្ទះនេះ ត្រូវផុតពីសមត្ថកិច្ចរបស់លោកសេង សាញ់ ដែលជាចៅសង្កាត់ទៅហើយ ។

-យល់ឃើញថា ការដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា លោកសេង សាញ់ ត្រូវទទួលខុសត្រូវចំពោះការចូលមកស្នាក់នៅរបស់ប្រជាជនផ្សេងទៀតនោះ បើរឿងមានពិតមែននោះវាជារឿងរដ្ឋបាល ពុំមែនជាបទអាជ្ញាទេ ពីព្រោះពុំមានភស្តុតាងណាបញ្ជាក់ថា លោកសេង សាញ់ រួមគំនិតក្នុងការចាត់ចែងផ្ទះ ដែលតុលាការបានហាមឃាត់នេះទេ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ២៦"ខ" ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទំរង់ ទាំងគតិច្បាប់ហើយ ។

## ហេតុដូច្នេះ

**វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី :**

១-ទទួលបណ្តឹងសាទុក្ខលេខ១១១ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៥ របស់អ្នកស្រី សុខ ពៅ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ២៦"ខ" ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៥ របស់សាលា-ឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៦ ។